អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

General Department of Customs and Excise of Cambodia



# កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងកម្ពុជា-អេមីរ៉ែតអារ៉ាប់រួម

## បទបង្ហាញស្តីពី
## ជំពូកទី ៤ ÷ នីតិវិធីគយនិងកិច្ចសម្រួលពាណិជ្ជកម្ម

**ជា សំណាង**, ប្រធានក្រុមចរចា

ក្រុមការងារនីតិវិធីគយនិងកិច្ចសម្រួលពាណិជ្ជកម្ម

រាជធានីភ្នំពេញ ,ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤

# មាតិកា

I. សេចក្តីផ្តើម

II. បញ្ញាតិនៃកិច្ចព្រមព្រៀង៖ នីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម

III. វិធានការនៃកិច្ចសម្រួលពាណិជ្ជកម្ម

# I. សេចក្តីផ្តើម

- គោលការណ៍ការនៃការចរចាផ្អែកលើ ÷ កិច្ចព្រមព្រៀងអន្តរជាតិ, កិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី, និងអនុលោមតាម ច្បាប់ វិធាន និងបទប្បញ្ញត្តិជាតិរបស់ភាគីនីមួយៗ
- ក្រុមការងារបានរៀបចំជំហរ និង ឯកសារចរចាដោយផ្អែកលើ ÷
  - កិច្ចព្រមព្រៀង CKFTA,, កិច្ចព្រមព្រៀង UAE-India CEPA របស់ UAE
  - កិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO TFA)
  - ក្រោមកិច្ចព្រមព្រៀង ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)
- ចរចាជុំទី១នៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០២២ និងបញ្ចប់ការចរចានៅជុំទី៣នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០២៣ (៥ខែ) ដោយបានឯកភាពគ្នា ចំនួន ១៦ មាត្រា

# CAMBODIA and WTO TFA










Source: www.tfadatabase.org/en/members/cambodia

# Implementation Progress




**Remaining Category C**

- Art7.1 Pre-arrival Processing
- Article 8.2 Border Agency Cooperation (External)
- Art10.4 Single Window
- Art 11.5 Freedom of Transits: "To make available, where practicable, physically separate infrastructure.."

**Early Completion of Cat. C**

- Art1.4 Notification
- Art7.7 Trade Facilitation Measures for Authorized Operator

# II. បញ្ញត្តិនៃកិច្ចព្រមព្រៀងៈ នីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម

1. និយមន័យ
2. វិសាលភាព
3. បទប្បញ្ញត្តិទូទៅ
4. ការបោះពុម្ពផ្សាយ និងការទទួលបានព័ត៌មាន
5. ការគ្រប់គ្រងហានិភ័យ
6. ការទំនាក់ទំនងដោយពុំប្រើក្រដាសស្នាម
7. វិធានបញ្ជាក់ជាមុន
8. ការពិន័យ
9. ការបញ្ចេញទំនិញ
10. ប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត
11. កិច្ចសហប្រតិបត្តិការភ្នាក់ងារព្រំដែន
12. ការដឹកជញ្ជូនរហ័ស
13. ការត្រួតពិនិត្យឡើងវិញ និងប្ដឹងតវ៉ា
14. កិច្ចសហប្រតិបត្តិការគយ
15. ព័ត៌មានសម្ងាត់
16. អនុគណៈកម្មការស្ដីពីនីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម

## មាត្រា ៤.២ ÷ វិសាលភាព

ជំពូកនេះត្រូវអនុវត្តដោយអនុលោមតាម ច្បាប់ វិធាន និងបទប្បញ្ញត្តិជាតិរបស់ភាគីនីមួយៗ និងនីតិវិធី គយ ដែលតម្រូវសម្រាប់បញ្ចេញទំនិញពីគយដែលធ្វើពាណិជ្ជកម្មរវាងភាគី និងមធ្យោបាយដឹកជញ្ជូន ដែលចូល ឬ ចេញពីដែនគយ នៃភាគីនីមួយៗ។

# មាត្រា៤.៣ ÷ បទប្បញ្ញត្តិទូទៅ

- ត្រូវមានតម្លាភាព មិនមានភាពរើសអើង សង្គតិភាព និងជៀសវាងឧបសគ្គមិនចាំបាច់នានាសម្រាប់ពាណិជ្ជកម្ម។
- ត្រូវអនុវត្តដោយអនុលោមតាមកាតព្វកិច្ចរបស់ភាគីនីមួយៗ ក្រោមកិច្ចព្រមព្រៀង អង្គការពាណិជ្ជកម្មពិភពលោកស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម ដោយពិចារណាពីកម្រិតផ្សេងៗគ្នានៃភាពរួចរាល់ក្នុងការអនុវត្ត។
- នីតិវិធីគយរបស់ភាគីនីមួយៗត្រូវអនុលោមតាមស្តង់ដា និងអនុសាសន៍នៃការអនុវត្តរបស់អង្គការគយពិភពលោក (WCO) ។
- ត្រូវពិនិត្យឡើងវិញជាប្រចាំ នូវនីតិវិធីគយ ក្នុងគោលបំណងធ្វើឲ្យមានសាមញ្ញកម្ម និងសម្រួលពាណិជ្ជកម្មទ្វេភាគីបន្ថែមទៀត។

# មាត្រា៤.៤ ÷ ការបោះពុម្ពផ្សាយ និងការទទួលបានព័ត៌មាន

១. ច្បាប់ បទប្បញ្ញត្តិ គោលការណ៍ណែនាំ នីតិវិធី និងវិធានរដ្ឋបាល ដែលពាក់ព័ន្ធកិច្ចការគយត្រូវបោះពុម្ពផ្សាយភ្លាមៗទាំងនៅលើអ៊ីនធឺណិត ឬក្នុងទម្រង់បោះពុម្ពជាភាសាអង់គ្លេស ។

២. ត្រូវកំណត់បង្កើត និងរក្សានូវទីកន្លែងសាកសួរមួយ ឬច្រើន ដើម្បីដោះស្រាយសំណួរពីបុគ្គលពាក់ព័ន្ធអំពីកិច្ចការគយ និងត្រូវខិតខំផ្សព្វផ្សាយជាសាធារណៈតាមរយៈមធ្យោបាយអេឡិចត្រូនិកនូវ ព័ត៌មានទាក់ទងនឹងនីតិវិធីសម្រាប់ការសាកសួរនេះ។

៣. មិនមានតម្រូវឲ្យបោះពុម្ពផ្សាយ អំពីនីតិវិធីអនុវត្តច្បាប់ និងគោលការណ៍ណែនាំប្រតិបត្តិការផ្ទៃក្នុង រួមទាំងការវិភាគហានិភ័យនិងវិធីសាស្ត្រកំណត់គោលដៅឡើយ។

៤. ច្បាប់ និងបទប្បញ្ញត្តិថ្មី ឬធ្វើវិសោធនកម្មនៃការអនុវត្តទូទៅពាក់ព័ន្ធ នឹងចរាចរ ការបញ្ចេញ និងការបំពេញបែបបទបញ្ចេញទំនិញពីគយ រួមទាំងទំនិញឆ្លងកាត់ ត្រូវបោះពុម្ពផ្សាយ ឬព័ត៌មានទាំងនោះ ត្រូវផ្សព្វផ្សាយជាសាធារណៈឲ្យបានឆាប់តាមដែលអាចធ្វើទៅបានមុនពេលចូលជាធរមាន ។

៥. ការផ្លាស់ប្តូរអត្រាពន្ធ ឬអត្រាពន្ធគយ, វិធានការដែលមានប្រសិទ្ធភាពធូរស្រាល, ការវាស់វែង ប្រសិទ្ធភាព ដែលនឹងធ្វើឲ្យប៉ះពាល់ពីលទ្ធផលនៃការអនុលោមតាមកថាខណ្ឌទី៤, វិធានការដែលបានអនុវត្តក្នុងកាលៈទេសៈបន្ទាន់ ឬការផ្លាស់ប្តូរតិចតួចចំពោះច្បាប់ និងប្រព័ន្ធច្បាប់ដែល ត្រូវបានលើកលែងពីកាតព្វកិច្ច ក្នុងកថាខណ្ឌទី១ និងទី៤។

# PUBLICATION AND AVAILABILITY OF INFORMATION
























GET IT ON Google Play

Download on the App Store




GET IT ON Google Play

CUSTOMS CLEARANCE

Download on the App Store

WWW.customs.gov.kh

# PUBLICATION AND AVAILABILITY OF INFORMATION











# NCTF Website and National Trade Repository









# Cambodia Enquiry Points






# មាត្រា ៤.៥ ÷ ការគ្រប់គ្រងហានិភ័យ

ភាគីនីមួយៗត្រូវអនុម័ត វិធីសាស្ត្រគ្រប់គ្រងហានិភ័យនៅក្នុងកិច្ចការគយ ដោយផ្អែកលើសូចនាករ ហានិភ័យនៃទំនិញពាក់ព័ន្ធ ដើម្បីសម្រួលពាណិជ្ជកម្មក្នុងការបញ្ចេញទំនិញដែលមានហានិភ័យទាប ខណៈផ្តោត ការត្រួតពិនិត្យគយលើទំនិញដែលមានហានិភ័យខ្ពស់។



# មាត្រា៤.៦ ការទំនាក់ទំនងដោយពុំប្រើក្រដាសស្នាម

១. សម្រាប់គោលបំណងនៃការសម្រួលពាណិជ្ជកម្ម ភាគីត្រូវព្យាយាមផ្តល់នូវបរិយាកាស អេឡិចត្រូនិក ដែលគាំទ្រដល់ប្រតិបត្តិការធុរកិច្ចរវាងរដ្ឋបាលគយ និងអង្គភាពពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់ វិធាន និងបទប្បញ្ញត្តិជាតិរៀងៗខ្លួនរបស់ភាគី។

២. ភាគីនីមួយៗត្រូវផ្លាស់ប្តូរគំនិត និងព័ត៌មានស្តីពីការសម្រេច និងលើកកម្ពស់ការទំនាក់ទំនងដោយពុំប្រើក្រដាសស្នាមរវាងរដ្ឋបាលគយរៀងៗខ្លួន និងអង្គភាពពាណិជ្ជកម្មរបស់ពួកគេ។

៣. ក្នុងការអនុវត្តគំនិតផ្តួចផ្តើមនៃការប្រើប្រាស់ទំនាក់ទំនងដោយពុំប្រើក្រដាសស្នាម រដ្ឋបាលគយរបស់ ភាគីនីមួយៗ ត្រូវគិតគូរពីវិធីសាស្ត្រដែលបានព្រមព្រៀងនៅក្នុងអង្គការគយពិភពលោក (WCO)។

# DIGITAL TRANSFORMATION MILESTONES

- ASYUCDA World — 2008
- E-Customs — 2015
- Mobile Applications — 2017
- E-Payment — 2018
- NSW Phase 1&2 and joint ASW — 2019

- ASEAN Customs Transit — 2020
- Passenger Targeting Sys. (GTAS) — 2022
- Full Digital Customs Clearance — JAN 2024
- Pre-Arrival Processing — MAR 2024
- NSW Phase 3 Official Launching — 7 MAY 2024

# RECENT UPDATES IN REGULATIONS

## Electronic Data Flow For Customs Clearance



# មាត្រា៤.៧ ÷ វិធានបញ្ជាក់ជាមុន

១. អនុលោមតាមការសន្យារបស់ខ្លួនក្រោមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម ភាគីនីមួយៗត្រូវចេញវិធានបញ្ជាក់ជាមុន ដល់អ្នកនាំចូលទំនិញក្នុងដែនដីរបស់ខ្លួន ឬអ្នកនាំចេញ ឬអ្នកផលិតទំនិញនៅក្នុងដែនដីនៃភាគីផ្សេងទៀតមុនពេលការនាំចូលទំនិញចូលទៅក្នុងដែនដីរបស់ខ្លួន។

២. សម្រាប់គោលបំណងនៃកថាខណ្ឌទី១ ភាគីនីមួយៗត្រូវចេញវិធាន ថាតើទំនិញមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ជាទំនិញដែលមានដើមកំណើត ឬដើម្បីវាយតម្លៃចំណាត់ថ្នាក់ទំនិញ។ លើសពីនេះទៀត ភាគីនីមួយៗ អាចចេញវិធានដែលគ្របដណ្តប់លើបញ្ហាពាណិជ្ជកម្មបន្ថែម ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងកិច្ចសម្រួលពាណិជ្ជកម្ម TFA។ ភាគីនីមួយៗត្រូវចេញសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងដើមកំណើត ឬការចាត់ថ្នាក់ទំនិញ ក្នុងរយៈពេលមួយសមរម្យ គិតចាប់ពីការពីថ្ងៃដែលទទួលបានពេញលេញនូវពាក្យស្នើសុំវិធានបញ្ជាក់ជាមុន។

# នីតិវិធី វិធានបញ្ជាក់ជាមុន

**ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៣**

វិធានបញ្ជាក់ជាមុនលើការចាត់ថ្នាក់ទំនិញ

**ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤**

វិធានបញ្ជាក់ជាមុនលើដើមកំណើតទំនិញ

**ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៣**

វិធានបញ្ជាក់ជាមុនលើតម្លៃគិតពន្ធគយ

វិធានបញ្ជាក់ជាមុន ត្រូវបានបង្កើតនិងដាក់អនុវត្តនៅកម្ពុជា ចាប់ពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៣ ក្នុងគោលបំណងដើម្បីលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម ។

**ការពិនិត្យឡើងវិញនូវវិធានបញ្ជាក់ជាមុនលើចំណាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ**




ទាញយក៖វិធានបញ្ជាក់ជាមុនលើលេខកូដទំនិញដែលធ្លាប់បានធ្វើការសម្រេច

https://api.customs.gov.kh/wp-content/uploads/2015/05/registration-advance-ruling-on-hs.pdf

# នីតិវិធី វិធានបញ្ជាក់ជាមុន

| year | advance ruling on Hs | advance ruling on CV |
|---|---|---|
| 2013 | 4 | 0 |
| 2014 | 2 | 0 |
| 2015 | 15 | 0 |
| 2016 | 80 | 0 |
| 2017 | 45 | 0 |
| 2018 | 1 | 2 |
| 2019 | 7 | 0 |
| 2020 | 9 | 0 |
| 2021 | 10 | 0 |
| 2022 | 21 | 0 |
| 2023 | 13 | 0 |
| 2024 | 7 | 0 |
| total | 214 | 2 |

# មាត្រា៤.៨ ÷ ការពិន័យ

១. ត្រូវរក្សានូវវិធានការដាក់ពិន័យព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬពិន័យរដ្ឋបាល ទោះបីតែមួយ ឬរួមបញ្ចូលគ្នាចំពោះការបំពានច្បាប់ បទប្បញ្ញត្តិគយ ឬការតម្រូវនូវនីតិវិធីណាមួយរបស់ភាគី។

២. ត្រូវធានាថា រាល់ការពិន័យដែលចេញសម្រាប់ការបំពានលើច្បាប់បទប្បញ្ញត្តិគយ ឬការ តម្រូវនីតិវិធីត្រូវបានដាក់តែលើបុគ្គលដែលបំពានក្រោមច្បាប់របស់ខ្លួនតែប៉ុណ្ណោះ។

៣. ត្រូវធានាថា ការពិន័យដោយរដ្ឋបាលគយរបស់ខ្លួនគឺផ្អែកលើអង្គហេតុ និងកាលៈទេសៈ នៃករណីដែលសមស្របជាមួយកម្រិត និងភាពធ្ងន់ធ្ងរនៃការបំពាន។

៤. ត្រូវធានាថាខ្លួនរក្សាបាននូវវិធានការដើម្បីជៀសវាងការប៉ះទង្គិចផលប្រយោជន៍ ក្នុងការវាយតម្លៃនិងការប្រមូលប្រាក់ពិន័យ និងពន្ធ។

៥. ប្រសិនបើការពិន័យ ការពន្យល់ជាលាយលក្ខណ៍អក្សរត្រូវតែផ្តល់ឱ្យទៅ បុគ្គលដែលត្រូវបានដាក់ពិន័យនោះ ដោយបញ្ជាក់អំពីលក្ខណៈនៃការបំពានលើច្បាប់ បទប្បញ្ញត្តិគយ ឬការ តម្រូវនីតិវិធីសម្រាប់កំណត់ទំហំនៃការពិន័យ ។

# មាត្រា៤.៩ ÷ ការបញ្ចេញទំនិញពីគយ

១. ត្រូវអនុម័តឬប្រកាន់ខ្ជាប់នូវនីតិវិធីគយដែលសាមញ្ញសម្រាប់ការបញ្ចេញទំនិញពីគយប្រ
ដោយប្រសិទ្ធភាពដើម្បីសម្រួលពាណិជ្ជកម្ម។

២. យោងតាមកថាខណ្ឌទី១ ភាគីនីមួយៗ ត្រូវអនុម័ត ឬប្រកាន់ខ្ជាប់នីតិវិធីដែល៖

(ក) បញ្ចេញទំនិញភ្លាមៗនៅពេលទទួលបានប្រតិវេទន៍គយ និងការបំពេញតាមការតម្រូវ និង
វិធីទាំងអស់

(ខ) អនុញ្ញាតឱ្យមានការដាក់ និងដំណើរការឯកសារ និងទិន្នន័យ រួមទាំង អញ្ញត្តប័ណ្ណ ជាទម្រ
ឡិចត្រូនិក នៅមុនពេលការមកដល់នៃទំនិញ ដើម្បីពន្លឿនការបញ្ចេញទំនិញ ពីគយការ
ពិនិត្យគយនៅ ពេលទំនិញមកដល់

(គ) អនុញ្ញាតឲ្យបញ្ចេញទំនិញនៅពេលមកដល់ ដោយមិនចាំបាច់តម្រូវឱ្យមានកា
បណ្តោះអាសន្នទៅកាន់ ភណ្ឌាគារគយ ឬទីវេសនដ្ឋានផ្សេងទៀត និង

(ឃ) អនុលោមតាមច្បាប់របស់ខ្លួន ក្នុងករណីភាគីមិនបានបញ្ចេញទំនិញភ្លាមៗ ភាគីត្រូ
ដំណឹងទៅ អ្នកនាំចូល រួមទាំងមូលហេតុដែលទំនិញមិនត្រូវបានបញ្ចេញ និងបញ្ជាក់ភ្នាក់ង
ដែនមួយណា បើមិនមែនជារដ្ឋបាលគយ ដែលបានឃាត់ទុកការបញ្ចេញទំនិញនោះ។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
លេខ...........សហវ.............

ប្រកាស
ស្តីពី
នីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការ

# មាត្រា ៤.១០ ប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត

ភាគីនីមួយៗត្រូវខិតខំ <u>បញ្ជប់ប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត(AEO)</u> និងការរៀបចំ<u>ការទទួលស្គាល់គ្នាទៅវិញទៅមក( MRA )</u>រវាងរដ្ឋបាលគយរបស់ពួកគេ ដើម្បីជួយសម្រួលដល់ពាណិជ្ជកម្ម និងលើកកម្ពស់ការអនុលោមតាមច្បាប់ និងការគ្រប់គ្រងហានិភ័យរវាងទ្វេភាគី។







| Criteria | Revised BTIM | AEO |
|---|---|---|
| A. Demonstrated Compliance with Customs Requirements | ✓ | ✓ |
| B. Satisfactory System for Management of Commercial Records | ✓ | ✓ |
| C. Financial Viability | ✓ | ✓ |
| D. Consultation, Cooperation, and Communication | ✓ | ✓ |
| E. Education, Training, and Threat Awareness | ✓ | ✓ |
| F. Information Exchange, Access, and Confidentiality | ✓ | ✓ |
| G. Cargo Security | X | ✓ |
| H. Conveyance Security | X | ✓ |
| I. Premises Security | X | ✓ |
| J. Personnel Security | X | ✓ |
| K. Trading Partner Security | X | ✓ |
| L. Crisis Management and Incident Recovery | X | ✓ |
| M. Measurement, Analysis, and Improvement | X | ✓ |

# ប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត

ជំហានទី ៣

កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត (អនុលោមភាព និង សុវត្ថិភាព) (កម្រិតថ្នាក់ជាតិ)

ជំហានទី ២

កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត (អនុលោមភាព និង សុវត្ថិភាព) (ការសាកល្បង)

ជំហានទី ១

យន្តការលើកទឹកចិត្តធុរជនល្អបំផុតដែលកែសម្រួល (អនុលោមភាព)

បច្ចុប្បន្ន

យន្តការលើកទឹកចិត្តធុរជនល្អបំផុត

អនុលោមក្របខណ្ឌស្តង់ដារសុវត្ថិភាពរបស់អង្គការគយពិភពលោក

អនុលោមកិច្ចព្រមព្រៀងសម្រួលពាណិជ្ជកម្ម


ប្រការ១៧._ ការអនុវត្ត

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឆ្នាំ២០២៣

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី - ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ ១៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

១០/១០

# ផលប្រយោជន៍
# ប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត

Destination Clearance and use of AEO logo

Fewer Physical and Document-based Control

Deferred Payment (15 Days)

CAMBODIA

Authorized Economic Operator

Priorities Customs Clearance

M.R.A

BENEFITS

# មាត្រា ៤.១១ ÷ កិច្ចសហប្រតិបត្តិការភ្នាក់ងារព្រំដែន

ភាគីនីមួយៗត្រូវធានាថា អាជ្ញាធរ និងភ្នាក់ងាររបស់ខ្លួនដែលទទួលខុសត្រូវលើការគ្រប់គ្រួតពិនិត្យនិងអនុវត្តនីតិវិធីព្រំដែន ពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ និងការដឹកជញ្ជូនឆ្លងកាត់ សហការគ្នាទៅវិញទៅមក និងសម្របសម្រួលសកម្មភាពការងារជាមួយគ្នា ដើម្បីសម្រួលពាណិជ្ជកម្មស្របតាមបញ្ញត្តិនៃជំពូកនេះ។

# មាត្រា៤.១២៖ ការដឹកជញ្ជូនរហ័ស

១. ត្រូវអនុម័ត ឬប្រកាន់ខ្ជាប់នូវនីតិវិធីគយរហ័ស សម្រាប់ទំនិញដែលនាំចូលតាម ឃ្លាំងទំនិញផ្លូវអាកាស ។ នីតិវិធីទាំងនេះត្រូវ៖

(ក) អនុញ្ញាតឲ្យដាក់ព័ត៌មានចាំបាច់ដើម្បីអាចបញ្ចេញទំនិញដឹកជញ្ជូនរហ័ស និងដំណើរការនីតិវិធីមុនពេលទំនិញមកដល់

(ខ) អនុញ្ញាតឲ្យមានការដាក់ព័ត៌មានតែមួយលើក ដែលគ្របដណ្តប់គ្រប់ទំនិញ នៅក្នុងការដឹកជញ្ជូនរហ័ស ដូចជានិវេទនប័ណ្ណតាមរយៈមធ្យោបាយអេឡិចត្រូនិច ប្រសិនបើអាចធ្វើទៅបាន

(គ) តាមលទ្ធភាពដែលអាចធ្វើបាន អនុញ្ញាតឲ្យបញ្ចេញទំនិញដោយតម្រូវឲ្យផ្តល់ឯកសារអប្បបរមាសម្រាប់មុខទំនិញដាក់លាក់មួយចំនួន

(ឃ) ក្នុងកាលៈទេសៈធម្មតា ផ្តល់នូវការបញ្ចេញទំនិញបញ្ញើរហ័សឲ្យបានលឿនតាមដែលអាចធ្វើទៅបាន បន្ទាប់ពីបានផ្តល់ឯកសារចាំបាច់នានាជូនអាជ្ញាធរគយ និងបន្ទាប់ពីទំនិញបានមកដល់

(ង) អនុវត្តចំពោះការដឹកជញ្ជូនមិនគិតពីទម្ងន់ ឬតម្លៃ...

(ច) ក្នុងកាលៈទេសៈធម្មតា ទំនិញដែលនាំចូលតាមការដឹកជញ្ជូនរហ័សដែលមានតម្លៃស្មើ ឬទាបជាងការកំណត់ដោយច្បាប់ជាតិរបស់ភាគីនាំចូល មិនត្រូវជាប់កាតព្វកិច្ចពន្ធទេឡើយ។

២. គ្មានអ្វីនៅក្នុងកថាខណ្ឌទី១ ត្រូវប៉ះពាល់ដល់សិទ្ធិរបស់ភាគីក្នុងការត្រួតពិនិត្យ ឃាត់ រឹបអូស ដកហូត ឬបដិសេធការចូលទំនិញ ឬធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ រួមទាំងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហានិភ័យ និងរារាំងបណ្តាភាគីពីការតម្រូវជាលក្ខខណ្ឌមុនការបញ្ចេញទំនិញ នូវការផ្តល់ព័ត៌មានបន្ថែម និងការបំពេញតម្រូវការនៃការអនុញ្ញាតដែលមិនស្វ័យប្រវត្តិឡើយ។

# WCO Immediate Release Guidelines






## ក.បញ្ញើប្រភេទទី១

បញ្ញើប្រភេទទី១សំដៅដល់សំបុត្រ ឬឯកសារ គ្មានតម្លៃលក្ខណៈពាណិជ្ជកម្ម និងមិនស្ថិតក្នុងបញ្ជីទំនិញហាមឃាត់ ឬទំនិញជាប់កម្រិតកំណត់។ បញ្ញើប្រភេទទី១ពុំជាប់កាតព្វកិច្ចពន្ធនិងអាករឡើយ។ អញ្ញាតបណ្ណរងអេឡិចត្រូនិក ឬ ទិន្នន័យអេឡិចត្រូនិកទម្រង់ CN22/CN23 របស់បញ្ញើប្រភេទទី១នេះអាចចាត់ទុកជាប្រតិវេទន៍គយ និងសម្រាប់ជាមូលដ្ឋានក្នុងការវាយតម្លៃហានិភ័យ។ ក្នុងករណីពុំមានហានិភ័យឬភាពមិនប្រក្រតី បញ្ញើប្រភេទទី១អាចអនុញ្ញាតឱ្យយកចេញពីគយភ្លាមក្រោយពេលមកដល់។

## ខ.បញ្ញើប្រភេទទី២

បញ្ញើប្រភេទទី២សំដៅដល់បញ្ញើដែលមានតម្លៃ (FOB) តិចជាងឬស្មើតម្លៃទំនិញមានតម្លៃទាប (De Minimis) និងមិនស្ថិតក្នុងបញ្ជីទំនិញហាមឃាត់ ឬទំនិញជាប់កម្រិតកំណត់។ បញ្ញើប្រភេទទី២ពុំជាប់កាតព្វកិច្ចពន្ធនិងអាករឡើយ។ អញ្ញាតបណ្ណរងអេឡិចត្រូនិក ឬទិន្នន័យអេឡិចត្រូនិកទម្រង់ CN22/CN23 របស់បញ្ញើប្រភេទទី២នេះអាចចាត់ទុកជាប្រតិវេទន៍គយ និងសម្រាប់ជាមូលដ្ឋានក្នុងការវាយតម្លៃហានិភ័យ។ ក្នុងករណីពុំមានហានិភ័យឬភាពមិនប្រក្រតី បញ្ញើប្រភេទទី២អាចអនុញ្ញាតឱ្យយកចេញពីគយភ្លាមក្រោយពេលមកដល់។

## គ.បញ្ញើប្រភេទទី៣

បញ្ញើប្រភេទទី៣សំដៅដល់បញ្ញើដែលមានតម្លៃ (FOB) លើសតម្លៃទំនិញមានតម្លៃទាប (De Minimis) ប៉ុន្តែមានតម្លៃសមមូលមិនលើសពី ១,០០០ (មួយពាន់) ដុល្លារអាមេរិក និងមិនស្ថិតក្នុងបញ្ជីទំនិញហាមឃាត់ ឬទំនិញជាប់កម្រិតកំណត់។ បញ្ញើប្រភេទទី៣ជាកម្មវត្ថុនៃការប្រកាសប្រតិវេទន៍គយសង្ខេប និងត្រូវបំពេញកាតព្វកិច្ចពន្ធនិងអាករ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ឃ.បញ្ញើប្រភេទទី៤

បញ្ញើប្រភេទទី៤សំដៅដល់បញ្ញើមិនស្ថិតក្នុងបញ្ញើប្រភេទទី១ បញ្ញើប្រភេទទី២ និងបញ្ញើប្រភេទទី៣ ខាងលើ។ បញ្ញើប្រភេទទី៤ជាកម្មវត្ថុនៃការប្រកាសប្រតិវេទន៍គយ (ឯកសាររដ្ឋបាលតែមួយ) និងត្រូវបំពេញកាតព្វកិច្ចពន្ធនិងអាករស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

# មាត្រា ៤.១៣ ÷ ការត្រួតពិនិត្យឡើងវិញ និងប្ដឹងតវ៉ា

១. ភាគីនីមួយៗត្រូវធានាថាបុគ្គលណាមួយដែលខ្លួនចេញសេចក្ដីសម្រេចលើបញ្ហាគយមានសិទ្ធិ ៖

(ក) ស្នើសុំការត្រួតពិនិត្យរដ្ឋបាលឡើងវិញយ៉ាងហោចណាស់មួយកម្រិតលើការកំណត់ដោយរដ្ឋបាលគយរបស់ខ្លួនដែលឯករាជ្យ ពីមន្ត្រី ឬការិយាល័យដែលទទួលខុសត្រូវចំពោះសេចក្ដីសម្រេចដែលកំពុងត្រួតពិនិត្យ និង

(ខ) ស្នើសុំការត្រួតពិនិត្យឡើងវិញតាមផ្លូវតុលាការ លើសេចក្ដីសម្រេចដែលបានធ្វើឡើងដោយកម្រិតចុងក្រោយនៃការត្រួតពិនិត្យរដ្ឋបាល

២. ភាគីនីមួយៗត្រូវធានាថានីតិវិធីរបស់ខ្លួនសម្រាប់ការត្រួតពិនិត្យឡើងវិញនិងការប្ដឹងតវ៉ា ត្រូវបានអនុវត្តដោយមិនរើសអើង និងទាន់ពេលវេលា។

៣. ភាគីនីមួយៗត្រូវធានាថាអាជ្ញាធរដែលធ្វើការពិនិត្យឡើងវិញ ឬបណ្ដឹងតវ៉ាក្នុងកថាខណ្ឌទី១ ជូនដំណឹង ជាលាយលក្ខណ៍អក្សរអំពីការកំណត់ ឬសេច

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

General Department of Customs and Excise of Cambodia



# Thank You
# For Your Attention

Chea Samnang
Deputy Director of International Customs Cooperation Department
General Department of Customs and Excise of Cambodia

cheasamnang@customs.gov.kh
cheasamnang@gmail.com
012840895